ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤២៨**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Sep-2016, 15:44
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម ធូ មណី

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ាយ

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៊ិចឌ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក មាស សឿន (2-TCW-917) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ៖ លោក មាស សឿន** (2-TCW-917)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ............ ទំព័រ ២

សួរដោយលោក គង់ សំអុន ផ្តើមពី ............ ទំព័រ ១៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៤២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្ម មាស សឿន បញ្ចប់។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែលោកស្រី អង់តា ហ្គីសសេ មេធាវីការពារក្ដីឲ្យលោក ខៀវ សំផន អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក មាស សឿន។ លោក និងមេធាវីប្រឹក្សារបស់លោក គឺលោកស្រី សុក សុជាតា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មិនមានសាក្សីបម្រុងទេ។ សូមអរគុណលោកប្រធាន។

[០៩:០២:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ុយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណុំរឿងរបស់ជនជាប់ចោទ នួន ជា ជាសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ដែលបាន

បញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ ក្នុងបន្ទប់សវនាការនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈតឹងច្រមុះ ហៀរសម្បោរ ឈឺចង្កេះ វិលមុខពេលដើបឈរ ឬអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយ ស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈសវនាការពេញមួយថ្ងៃនេះ។

[០៩:០៣:៥៧]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ លោកសាក្សី កាលពីម្សិលមិញ ខ្ញុំបានបង្ហាញលោកនូវខ្សែភាពយន្តឯកសារដែល ប៉ុល ពត ចុះទៅធ្វើទស្សនកិច្ចនៅភូមិភាគបូព៌ា ប្រហែលជានៅដើមឆ្នាំ១៩៧៨។ ក្នុង

រូបនេះ គឺឃើញមាន ប៉ុល ពត ជាមួយនឹង សោ ភឹម។ ហើយកាលពីម្សិលមិញ លោកថា លោកស្គាល់ សោ ភឹម ច្បាស់ណាស់។ ហើយខ្ញុំក៏បានកត់សម្គាល់ផងដែរ ប៉ុន្តែជួយកែតម្រូវខ្ញុំ ក្រែងលោខ្ញុំច្រឡំ។ លោកថា លោកមានអារម្មណ៍ក្ដុកក្ដួលនៅពេលដែលឃើញខ្សែភាពយន្តឯកសារនេះ។

លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបង្ហាញខ្សែភាពយន្តឯកសាររយៈពេល២នាទីនេះ ម្តងទៀត ហើយខ្ញុំសូមឲ្យលោកសាក្សីមើលទៅលើបុគ្គលម្នាក់ដែលដើរជាប់នឹង ប៉ុល ពត។ ហើយបើសិនជាលោកសាក្សីអាចផ្តោតផ្ចង់អារម្មណ៍មើលតែបុគ្គលដែលដើរជាប់ ប៉ុល ពត គឺថាខ្ញុំរីករាយ។ បាទ លោកប្រធាន សូមការអនុញ្ញាខ្សែភាពយន្តឯកសារដែលមានរយៈពេល២នាទីនេះឡើងវិញ។

[០៩:០៦:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ លោកទើបតែនិយាយថា លោកគិតថា ខ្សែភាពយន្តហ្នឹងថតនៅឆ្នាំ៧៨ ខ្ញុំមិនដឹងច្បាស់អំពីឆ្នាំហ្នឹងទេ។ អ៊ីចឹងលោកមានមូលដ្ឋានអី បានជាលោកប៊ានអះអាងថា ខ្សែភាពយន្តហ្នឹងថតនៅឆ្នាំ១៩៧៨?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក៏វាមិនច្បាស់លាស់ទាំងស្រុងដែរ លោកប្រធាន។ ការដែលខ្ញុំថា វាជាខ្សែភាពយន្តឯកសារផលិតនៅឆ្នាំ១៩៧៨ គឺខ្ញុំបានឯកសារមកពីមជ្ឈមណ្ឌលបុប្ផាណា <ដែលមិនមាននៅក្នុងសំណុំរឿងទេ ប៉ុន្តែមានលេខ ERNជាភាសា>អង់គ្លេស<> គឺ 00422113។ ខ្ញុំឃើញមានលេខ D ដែរគឺ D285/2/2 ហើយជាភាសាបារាំងនិយាយថា "ប៉ុល ពត ធ្វើទស្សនកិច្ចនៅចម្ការកៅស៊ូ<>ផលិត<នៅឆ្នាំ ១៩៧៨។" ខ្ញុំមិនដឹងថា វាត្រឹមត្រូវឬក៏អត់នោះទេ ដូច្នេះហើយទើបខ្ញុំមានការបម្រុងទុកជាមុនមួយចំនួន ដូចជាខ្ញុំនិយាយថា> នៅ<ដើម>ឆ្នាំ១៩៧៨។ ឆ្នាំដែលផលិតឯកសារនេះ គឺដើមឆ្នាំ១៩៧៨។ នេះឯងដែលខ្ញុំមកសំអាងឯកសារនេះ គឺយ៉ាងដូច្នេះឯងលោកចៅក្រម។

[០៩:០៧:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យចាក់បង្ហាញនូវផ្នែកឃ្លីបវីដេអូ តាមសំណើសុំរបស់សហមេធាវី

01329950



ការពារក្តីលោក នួន ជា សាជាថ្មីម្តងទៀត។ ផ្នែកដែលពាក់ព័ន្ធដែលគាត់ស្នើ ហើយឃ្លីបវីដេអូនេះបាន ផ្សព្វផ្សាយកាលម្សិលមិញម្តងហើយ តើអាចធ្វើទាន់ រកឃើញ ហើយធ្វើទាន់ដែរទេ? បើមិនទាន់វាយ ប្រាប់យើងវិញណា។

ផ្នែកសោតទស្សន៍ចាក់ផ្សាយខ្សែភាពយន្តតាមសំណើសុំរបស់សហមេធាវីការពារក្តី។ ឯកសារ នោះបានចាក់ពីម្សិលមិញហើយ ហើយសូមសាក្សីសូមផ្តង់មើលមនុស្ស រូបមនុស្សដែលនៅក្នុងខ្សែ ភាពយន្តនោះ ជាពិសេសមនុស្សម្នាក់ដែលដើរនៅទន្ទឹមគ្នាពីក្រោយបន្តិចជាមួយនឹង ប៉ុល ពត។

[០៩:០៨:៥៤]

*(ការបង្ហាញឯកសារជាខ្សែវីដេអូ)*

[០៩:១១:១៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកមានឱកាសបានពិនិត្យមើលខ្សែភាពយន្តឯកសារនេះម្តងទៀតហើយ។ តើលោកអាចស្គាល់មនុស្សម្នាក់ដើរក្បែរ ប៉ុល ពត ហើយពេលខ្លះដើរខាងក្រោយ ប៉ុល ពត តែម្តង?

**លោក មាស សឿន៖**

**ឆ៖** បាទ អរគុណ។ ខ្ញុំបានឃើញហើយ គឺរូបលោក សោ ភឹម។ អរគុណ។

**ស៖** ចុះលោកស្គាល់មនុស្សផ្សេងទៀតនៅក្នុងខ្សែភាពយន្តឯកសារនេះទេ?

**ឆ៖** អរគុណ។ មិនមានរូបណាមួយដែលខ្ញុំច្បាស់ពិតប្រាកដទៀតទេ។ អរគុណ។

**ស៖** កាលពីម្សិលមិញ ខ្ញុំបានបង្ហាញលោកអំពីរូបថតមួយ ទៅឲ្យលោកពិនិត្យមើល ហើយ លោកថាមើលទៅស្រដៀងឪពុករបស់លោក តែតាមការពិតគឺលោក ហេង សំរិន ទេ។ អ៊ីចឹងចុះនៅក្នុង ខ្សែភាពយន្តឯកសារនេះ លោកមើលឃើញ លោកស្គាល់ ហេង សំរិន ទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ដូចលោកសន្និដ្ឋានខ្លួនឯងទេ។ លោកចេះមកបន្តិចៗភស្តុតាងហើយ។ សាក្សីបាន ឆ្លើយច្បាស់ណាស់ គឺវាទំនងជាឪពុករបស់គាត់ ប៉ុន្តែបើធៀបជាមួយនឹងលោក ហេង សំរិន គឺខុសគ្នា ឆ្ងាយណាស់។ លោកពិនិត្យឯប្រតិចារឹកឡើងវិញ ចៀសវាងការបន្តំនូវភស្តុតាង ហើយយកមកសួរដេញ ដោលនៅចំពោះមុខសវនាការជាសាធារណៈដូច្នេះ។ បំភ្លៃភស្តុតាងហើយ។

[០៩:១៣:២០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានបំភ្លៃភស្តុតាងទេ។--

**ប្រធានអង្គជំនុំ៖**

លោកពិនិត្យមើលឡើងវិញ លើប្រតិចារឹកឡើងវិញ។ យើងគិតថាយើងបានស្តាប់ដោយយកចិត្តទុកដាក់ច្បាស់លាស់ណាស់។ ហើយសាក្សីបានឆ្លើយបញ្ជាក់យ៉ាងច្បាស់លាស់នូវចំណុចនេះ។ លោក --សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី បើលោកមានហេតុផលជឿជាក់ថាបុគ្គលហ្នឹងជា ហេង សំរិន លោកប្រាប់មូលហេតុមក។ ហេតុអីបានជាលោកគិតថា ម្នាក់ហ្នឹងជា ហេង សំរិន?

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារគេកត់សម្គាល់មើលទៅស្គាល់គាត់ច្បាស់ ឃើញរូបហ្នឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

នេះជាការសន្និដ្ឋានរបស់លោកផ្ទាល់ ជាការធ្វើសក្ខីកម្មដោយខ្លួនលោកផ្ទាល់ គឺថាមិនចាំបាច់ទេអីចឹងនោះ។

[០៩:១៤:១៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោក ហេង សំរិន គឺថាជាប្រមុខរដ្ឋនៅក្នុងឆ្នាំ១៩៧៩។ បុគ្គលិកខ្មែរនៅក្នុងក្រុមរបស់ខ្ញុំមើលទៅចំណាំមុខច្បាស់ហើយ ថាគឺលោក ហេង សំរិន ហើយ។ ប៉ុន្តែបើគាត់មើលមិនស្គាល់ទេ មិនថ្វីទេ។ ខ្ញុំចង់សាកសួរគាត់ម្តងទៀតថា រូបនេះជា ហេង សំរិន ឬក៏អត់ទេ ហើយបើគាត់ចាំបានក៏បាន មិនបានក៏មិនជាថ្វីដែរ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី មិនគប្បីលោកប្រើប្រាស់នូវផ្តល់សក្ខីកម្មរួច ហើយដឹកនាំឲ្យសាក្សីឆ្លើយទេ លោកតែងតែជំទាស់ភាគីដទៃទៀត ប៉ុន្តែផ្ទុយទៅវិញ លោកខ្លួនឯងបានប្រើប្រាស់នូវវិធីនេះនៅក្នុងករណីជាក់លាក់ជាច្រើន។ ហើយជាក់ស្តែងករណីនេះទៀតផង ដែលវាបន្ថែមលើសក្ខីកម្មរបស់សាក្សី បានឆ្លើយបញ្ជាក់រួចហើយកាលពីម្សិលមិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

កាលពីម្សិលមិញ ខ្ញុំសួរសំណួរបើកទេ ប៉ុន្តែចំណុចនេះមិនជាសំខាន់ណាស់ណាទេ ខ្ញុំសូមបន្ត ទៅមុខទៀតចុះ។

[០៩:១៥:៤៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីនៅពេល មុនយើងឈប់សម្រាកពីម្សិលមិញ ខ្ញុំបានសួរលោកពីមនុស្សម្នាក់ ឈ្មោះ អ៊ុក ប៊ុនឈឿន លោកបានឆ្លើយថា លោកស្គាល់គាត់។ ហើយ<យើងបាននិយាយអំពីអ្វីដែល> អ៊ុក ប៊ុនឈឿន បាននិយាយ<>អំពីឪពុករបស់លោក ហើយនិង ចាន់ ចក្រី។ ឥឡូវខ្ញុំព្យាយាមសាកសួរ ដោយអានសម្រង់ពេញលេញចេញពីសក្ខីកម្មរបស់គាត់តែម្ដង ឬក៏ថាជាកិច្ចសម្ភាសន៍របស់គាត់ជាមួយ នឹង ប៉ែន យៀរនិន។ នេះគឺឯកសារ E3/387, អង់គ្លេស00350211, បារាំង00441426, ខ្មែរ 00379493 ដល់494។ នេះគឺជាអ្វីដែល អ៊ុក ប៊ុនឈឿន គាត់បានឆ្លើយ គឺគាត់និយាយអំពី ចាន់ ចក្រី។ “ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំបានឮពី នួន ជា នៅក្នុងឆ្នាំ១៩៧៤ នៅពេលដែលគាត់បានអញ្ជើញកម្មាភិបាល ទាំងអស់ពីភូមិភាគបូព៌ា ឲ្យមកចូលរួមវគ្គរៀនសូត្រនៅភូមិស្វាយឃ្លាំង ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ។ នៅចុងបញ្ចប់នៃវគ្គរៀនសូត្រនេះ គឺគេតម្រូវឲ្យយើងពិនិត្យមើលអំពីជីវប្រវត្តិដោយជ្រើសរើសបុគ្គល ណាដែលជាគំរូ។ ចាន់ សេងហុង និង ចាន់ ចក្រី ត្រូវបានគេជ្រើសរើសថាជា បុគ្គលគំរូដោយសារនៅ ពេលនោះ ឆ្នាំ១៩៧៤ ចាន់ ចក្រី ក៏ក្លាយទៅជាមេកងពលទី១នៃភូមិភាគបូព៌ារួចទៅហើយ។” បញ្ចប់ការ ដកស្រង់។

តើសម្រង់នេះ ជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលថានៅឆ្នាំ១៩៧៤ នួន ជា បានចូល រួមប្រជុំ ដែលក្នុងនោះឪពុករបស់លោក ហើយនិង ចាន់ ចក្រី ត្រូវបានគេជ្រើសរើសឲ្យធ្វើជា បុគ្គលគំរូ នៅក្នុងជួរបដិវត្តន៍?

**លោក មាស សឿន៖**

**ឆ៖** បាទ ខ្ញុំមិនដែលឮទេ។ អរគុណ។

[០៩:១៨:៤០]

**ស៖** លោក អ៊ុក ប៊ុនឈឿន ដដែលនេះ ក៏បានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹង ប៉ែន យៀរនិន។ លោកប្រធាន នេះក្នុងឯកសារមួយផ្សេងទៀត E3/432, ERN ជាភាសាអង់គ្លេស 00542185, ខ្មែរ

00583878, បារាំង 00712076 ដល់77។ គេបានសួរ អ៊ុក ប៊ុនឈឿន អំពីឪពុករបស់លោក និង សោ ភឹម។ <គាត់និយាយថា> “ដូច្នេះ ប៉ុល ពត នេះគឺថា<លែង>ទុកចិត្ត សោ ភឹម ហើយគាត់យកអនុប្រធានភូមិភាគ<ឈ្មោះ ចាន់ ដើម្បីអប់រំ>ណែនាំ។ ហើយបន្ទាប់មក ចាន់ ក៏បានក្លាយទៅជាលេខាតំបន់ពីរ គឺ២៣ផង ២៤ផង ហើយក៏ឲ្យចាប់មនុស្សដែលមានឈ្មោះនៅក្នុងបញ្ជីដែលគេផ្ដល់មក។ <ចាប់តាំងពីការតស៊ូ>នយោបាយ ចាន់ <បាននៅ>ជិតដិតនឹង ប៉ុល ពត។ <ពួកគេនិយាយ>ថា <សោ ភឹម បាន>ការពារពួកក្បត់។ ដូច្នេះគេបានដាក់ឲ្យ ចាន់ ហ្នឹងគឺដើម្បីជាមូលដ្ឋានក្នុងការវាយប្រហារទៅដល់តំបន់៣ ផ្សេងទៀត។” បញ្ចប់ការដកស្រង់។ លោកសាក្សី អ៊ុក ប៊ុនឈឿន ហាក់បីដូចជាចង់បញ្ជាក់ឲ្យឃើញថា ឪពុករបស់លោកនេះនៅពេលមួយនោះ គឺជាប់ពាក់ព័ន្ធទៅនឹង ប៉ុល ពត ហើយប្រឆាំងជាមួយនឹង សោ ភឹម។ ខ្ញុំដឹងហើយថា កាលពីម្សិលមិញលោកបានឆ្លើយថា លោកអត់ដឹងរឿងនេះទេ ក៏ប៉ុន្តែខ្ញុំសួរថា តើរឿងនេះវាពិត ឬក៏មិនពិតទេ?

**ឆ៖** អរគុណ។ ខ្ញុំបាទមិនដឹងទេ។ អរគុណ។

**ស៖** ប៉ុន្មានបន្ទាត់ខាងក្រោមមកទៀត អ៊ុក ប៊ុនឈឿន ថាគឺឯកសារ <E3/432>ដដែល អង់គ្លេស 00542190, ខ្មែរ 00583887-88, បារាំង 00712083។ គាត់និយាយអំពីឪពុករបស់លោកដដែល ហើយគាត់ថា ចាន់ សេងហុង គឺជាអតីតខ្មែរឥស្សរៈ ហើយនៅភូមិភាគបូព៌ា គឺមានតែ ចាន់ សេងហុង ទេ ដែលស្មោះស្ម័គ្រជាមួយនឹង ប៉ុល ពត រហូតដល់ចុងបញ្ចប់។ តើលោកយល់យ៉ាងដូចម្ដេចដែរ ឬក៏មានប្រតិកម្មយ៉ាងដូចម្ដេចដែរ ចំពោះការលើកឡើងនេះ?

[០៩:២២:១៨]

**ឆ៖** ខ្ញុំគ្មានយល់យ៉ាងណាទេ ព្រោះខ្ញុំក៏មិនបានឮសម្ដីនេះផង។ បាទ អរគុណ។

**ស៖** ចម្លើយរបស់លោកគឺដដែលទេ។ ដើម្បីប្រតិចារឹកគឺថា ហេង សំរិន ដែលយើងទើបតែលើកឈ្មោះគាត់អម្បាញ់មិញនេះ បានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹង ប៉ែន យៀរនិន នេះគឺឯកសារ E3/1568 អង់គ្លេស 00651890, បារាំង 00743363, ខ្មែរ 00713964។ ហេង សំរិន គាត់បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “ចាន់ សេងហុង ពីដើមឡើយស្មោះស្ម័គ្រណាស់ ហើយក្រោយមក ប៉ុល ពត ដំឡើងបុណ្យស័ក្តិគាត់ ហើយ សោ ភឹម ត្រូវបានគេចោទថា ជាជនក្បត់។ ហើយមានមេបញ្ជាការកងពលដែលធ្វើការជាមួយ <ចាន់> សេងហុង ក៏ប្រាប់ថា ខ្លាំងបាន<>សម្លាប់<គាត់ហើយ>។” លោកសាក្សី លោកមានឯកសារនេះនៅចំពោះមុខហើយ។ តើលោកមាននៅចងចាំអំពីការចោទប្រកាន់

ថាមានការទំនាស់គ្នារវាងឪពុករបស់លោក ជាមួយនឹង សោ ភឹម, ហេង សំរិន, <អ៊ុក ប៊ុនឈឿន> និង ជា ស៊ីម ជាដើម។ល។?

**ឆ៖** បាទ អរគុណ។ ខ្ញុំមិនក្លាប់បានបញ្ហានេះទេ។ អរគុណ។

**ស៖** លោកសាក្សី លោកធ្លាប់ដែលឮថាតើ ប៉ុល ពត នេះខ្លាចមិនហ៊ានធ្វើដំណើរទៅកាន់ភូមិភាគបូព៌ាទេ លោកដែលឮទេ?

**ឆ៖** អរគុណ។ ខ្ញុំមិនដែលឮទេ។

[០៩:២៤:៥៥]

**ស៖** មានភស្តុតាងច្បាស់លាស់បញ្ជាក់ថាទាំង អ៊ុក ប៊ុនឈឿន, ទាំង អៀង សារី ហើយ នួន ជា ក៏បានឆ្លើយថា ប៉ុល ពត នេះខ្លាចណាស់ មិនហ៊ានទៅកាន់ភូមិភាគបូព៌ា ដោយសារភូមិភាគបូព៌ានេះទាក់ទងជិតដិតជាមួយនឹងវៀតណាម។ តើលោកមានបាននិយាយជាមួយនឹង សោ ភឹម ឬក៏មានទាក់ទងជាមួយនឹងឪពុករបស់លោក ហើយធ្លាប់ឮសួរអំពីចំណុចនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៏ ដេស្នាឯល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមជំទាស់ទៅនឹងសួរនេះ ពីព្រោះថាផ្នែកដំបូងនៃសំណួរ គឺជាសក្ខីកម្មរបស់មេធាវីការពារក្តី ដែលគាត់ថាមានភស្តុតាង ក៏ប៉ុន្តែអត់មានបង្ហាញអីសោះ។ ដូច្នេះគាត់គួរតែដកស្រង់ឃ្លាហ្នឹង ក៏ប៉ុន្តែនៅគាត់ដែលនិយាយថា “ប៉ុល ពត ខ្លាចមិនហ៊ានទៅភូមិភាគបូព៌ានោះ” មិនត្រឹមត្រូវទេ។ ត្រូវតែមានមូលដ្ឋានច្បាស់លាស់ក្នុងការលើកចំណុចនេះមកសួរ។ ដូច្នេះគាត់គួរតែដកស្រង់ភស្តុតាងណាមួយឲ្យបានជាក់លាក់ ដែលបង្ហាញឲ្យឃើញថា ប៉ុល ពត ពិតជាខ្លាចមិនហ៊ានទៅភូមិភាគបូព៌ាមែន។

[០៩:២៦:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

ជារៀងរហូតហ្នឹង ខ្ញុំមិនដែលប្រឌិតសាច់រឿងយ៉ាងដូច្នេះទេ។ ឥឡូវដើម្បីបំពេញបំណងរបស់សហព្រះរាជអាជ្ញារូបនោះ ខ្ញុំដកយកសក្ខីកម្មរបស់ លោក អ៊ុក ប៊ុនឈឿន គឺឯកសារ E3/387, ERN

ជាភាសាអង់គ្លេស 00350215, ខ្មែរ 00379499, បារាំង 00441432។ អ៊ុក ប៊ុនឈឿន បានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “ដោយសារតែ ប៉ុល ពត ខ្លាច សោ ភឹម គាត់ខ្លាច សោ ភឹម ដោយសារ សោ ភឹម មានឥទ្ធិពលខ្លាំងណាស់ទៅលើមនុស្សនៅភូមិភាគបូព៌ា។” នេះសម្រង់មួយ។

ហើយបន្ទាប់មកទៀត អៀង សារី បានសម្ភាសជាមួយនឹង ស្ទីវ ហេដឌ័រ ឯកសារ E3/89 អង់គ្លេស 00417608, បារាំង 00332690, ខ្ញុំមិនមាន ERN ជាភាសាខ្មែរទេ។ គាត់បានឆ្លើយដូចតទៅ៖ “សូម្បីតែ ប៉ុល ពត និង នួន ជា ខ្លួនឯងនេះ នៅពេល<ពួកគេនៅក្នុង>ភូមិភាគបូព៌ាហ្នឹង គឺថាពួកគាត់ខ្លាច តាភឹម ណាស់។ <ខ្ញុំបានទៅជាមួយពួកគេម្តង> ខ្ញុំដឹងហើយ ខ្ញុំឃើញរឿងនេះ គឺ ប៉ុល ពត ខ្លួនឯងនេះ មិនហ៊ានទៅមូលដ្ឋាននោះទេ ព្រោះគាត់ខ្លាច តាភឹម។ ដូច្នេះនៅក្នុងភូមិភាគនេះ បើ សោ ភឹម ចង់សម្លាប់អ្នកណា ឬក៏ចង់ធ្វើអ្វីមួយមិនចាំបាច់សួរថ្នាក់លើទេ គឺអង្គការចាត់តាំងយ៉ាងដូច្នេះឯង ភូមិភាគនីមួយៗគេឯករាជ្យ គឺថាភូមិភាគមួយៗ គេអាចសម្លាប់អ្នកណាតាមចិត្តដែលចង់សម្លាប់។”

ហើយឯកសារមួយទៀតលោកប្រធានគឺ ឯកសារ <E3/4202> <ដែលជាសៀវភៅរបស់ ថេត សម្បត្តិ>អង់គ្លេស 007 --

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាត ញាប់មិនអាចតាមទាន់ទេ។

**ប្រធានអង្គជំនុំ៖**

សាឡើងវិញជាថ្មី ទាំងលេខឯកសារ ទាំងលេខ ERN ហើយយឺតៗ ដើម្បីឲ្យអ្នកបកប្រែបកប្រែទាន់ផង។

[០៩:២៩:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធានសូមផ្តល់ម្តងទៀតគឺ E3/4202 អង់គ្លេស 00757528, បារាំង 00849428 មិនមាន ERN ជាភាសាខ្មែរទេ។ “<>ការស្វែងរកឃ្លាំង<ឃើញ>គឺថា មានការប៉ះពាល់ខ្លាំងណាស់ទៅលើ ប៉ុល ពត <ហើយគាត់តែងតែព្រួយបារម្ភថា គេអាចសម្លាប់គាត់>។ ជាពិសេស គាត់ខ្លាចណាស់មិនហ៊ានទៅកាន់ភូមិភាគបូព៌ាទេ។ ដោយសារតែអ្នកទាំងនោះគឺថា ជាប់ជិតដិតទាក់ទងជាមួយនឹងវៀតណាម។ នៅក្នុងពេលសវនាការខ្មែរក្រហម ឌុច បានលើកឡើងឯកសារ<ខែមីនា>ឆ្នាំ<៧៦ ដែលនិយាយ>ថា ប៉ុល ពត រៀបចំផែនការ<លើការប៉ុនប៉ង>សម្លាប់គាត់ ដោយបញ្ជូន ខៀវ សំផន ឬ នួន ជា

ឲ្យចូលរួមព្រឹត្តិការណ៍ណាមួយ តំណាងឲ្យគាត់។ នៅពេលជួបជាមួយនឹងមន្ត្រីកងទ័ពវៀតណាម តម្រូវឲ្យធ្វើដំណើរទៅកាន់វៀតណាម គឺថា នួន ជា ទេ ដែលជាអ្នកធ្វើដំណើរទៅនោះ។ សូមដកស្រង់--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់លោក!

អញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ នៅពេលដែលលោកដកស្រង់ឯកសារ អ្នកបកប្រែសូមឲ្យលោកអានយឺតៗ បើមិនអ៊ីចឹងទេ អ្នកបកប្រែ គាត់បកមិនទាន់ទេ ហើយយើងក៏មិនស្តាប់ឮអ្វីដែរ បើអ៊ីចឹងនោះ។

[០៩:៣០:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអានឲ្យយឺតបន្តិច ប៉ុន្តែសូមជម្រាបផងថា សហព្រះរាជអាជ្ញាក៏បានសួរបញ្ហានេះដែរ។ ខ្ញុំនឹងអានឡើងវិញម្តងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** "នៅពេលជួបប្រជុំជាមួយមន្ត្រីវៀតណាម តម្រូវឲ្យធ្វើដំណើរទៅកាន់ប្រទេសវៀតណាម នួន ជា តែងតែធ្វើដំណើរ -- ចូលតួនាទីនេះ ពីព្រោះគាត់ខ្លាចគេកម្ទេចចោល។ គាត់មិននិយាយទេ ប៉ុន្តែខ្ញុំដឹង ថាគាត់ខ្លាចណាស់។ នេះ នួន ជា គាត់និយាយយ៉ាងដូច្នេះ។" ដូច្នេះលោកសាក្សី ប្រភពឯកសារបីបញ្ជាក់ថា ប៉ុល ពត ខ្លាចមិនហ៊ានទៅជួប សោ ភឹម ទៅភូមិភាគបូព៌ាទេ។ តើមានចំណុចណាផ្សេងទៀត ដែលលោកអាចនឹកឃើញ ចងចាំ ឬក៏ធ្លាប់បានឮពីឪពុករបស់លោក ឬពីប្រភពណាមួយ អំពីថា ប៉ុល ពត ខ្លាចមិនហ៊ានទៅភូមិភាគបូព៌ានេះទេ?

**លោក មាស សឿន៖**

**ឆ៖** ខ្ញុំមិនធ្លាប់ឮទេ។ អរគុណ។

**ស៖** ឥឡូវនេះខ្ញុំត្រឡប់ទៅរកសក្ខីកម្មរបស់លោក ហេង សំរិន។ លោកសាក្សី ពីម្សិលមិញលោកនិយាយថា លោកដឹងពីលោក ហេង សំរិន ក្រោយឆ្នាំ១៩៧៩ទេ។ ប៉ុន្តែសូមអានឲ្យលោកស្តាប់មុននឹងសួរទៅលោក មុននឹងបញ្ជាក់ ដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតគឺ E3/5531។ គឺសំណួរ និងចម្លើយ៦២ សូមទោស។ លោកនិយាយថា នៅចំណុចមួយនោះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ

១៩៧៨ គឺថាលោកបានដឹកនាំទ័ពប្រហែលជា៥០០នាក់ទៅឲ្យសេនាធិការ ទៅខាងសេនាធិការ។ តើលោកនៅចាំថា លោកបាននិយាយបែបនេះទេ?

[០៩:៣៣:២៤]

**ផ៖** បាទ ចាំ។

**ស៖** ប៉ុន្តែនៅពេលនោះ ប៉ុន្តែលោកមិនស្គាល់ថាលោក ហេង សំរិន ជាបុគ្គលម្នាក់ដែលស្ថិតនៅក្នុងភូមិភាគបូព៌ា ហើយគាត់ជាសមាជិកនៅក្នុងសេនាធិការនោះទេ?

**ផ៖** បាទ ខ្ញុំនិយាយដូច្នេះមែន។

**ស៖** តើលោកស្គាល់អ្នកណាម្នាក់ទេ នៅក្នុងទីបញ្ជាការនៅក្នុងភូមិភាគបូព៌ា ទីបញ្ជាការយោធា ប៉ុន្តែជាអ្នកនៅក្នុងសេនាធិការរបស់គេនោះ លោកស្គាល់អ្នកណាម្នាក់ទេ?

**ផ៖** ខ្ញុំមិនស្គាល់អ្នកណាច្បាស់ទេ តែដឹងថា សេនាធិកាយោធាភូមិភាគបូព៌ាតាំងនៅទីរួមខេត្តព្រៃវែងបច្ចុប្បន្ន ពីកាលណោះ។ អរគុណ។

[០៩:៣៤:៤៧]

**ស៖** ខ្ញុំនឹងអានជូនលោកស្តាប់អំពីអ្វីដែលលោក ហេង សំរិន បាននិយាយ ដែលអាចនឹងរំឭកការចងចាំរបស់លោកបាន។ ខ្ញុំនឹងអានចេញពី E3/1568 ជាឯកសារអង់គ្លេស 00651888 ដល់ 89, ខ្មែរ 00713962, បារាំង 00743361 ដល់62 ខាងចុងបាទ។ ដូចដែលខ្ញុំនិយាយ គឺថាគាត់ផ្តល់សម្ភាសទៅឲ្យ ប៉ែន យៀវនិន។ លោក ហេង សំរិន គាត់បាននិយាយដូចខាងក្រោមនេះ៖ “នៅឆ្នាំ១៩៧៦ នៅថ្ងៃដែលជាខួបបក្សនោះ ជាខួបកំណើតបក្ស បង្កើតបក្ស ទូទាំងប្រទេសគេត្រូវលុបបំបាត់ចោលអ្នកដែលគេត្រូវប្រារព្ធពិធីបក្ស។ ហើយ ប៉ុល ពត បានចេញលិខិតសូមឲ្យបញ្ឈប់ការប្រារព្ធខួបកំណើតនេះ <ហើយរង់ចាំបទបញ្ជាបន្ថែមទៀត។ នៅពេលបទបញ្ជាចេញមក គេបាន>យក<>ឆ្នាំ១៩៦០ ជាថ្ងៃបង្កើតបក្ស។ ហើយនៅពេលនោះ យើងឃើញថាប៉ុល ពត បានធ្វើការកែទម្រង់ថ្មីដែលលុបចោលបក្សការតស៊ូរបស់បដិវត្តន៍ចាប់ពីឆ្នាំ១៩៥១មក។ <នៅឆ្នាំ>១៩៧៦, ៧៧ យើងមានការតស៊ូ ប៉ុន្តែជាការតស៊ូសម្ងាត់។<> ទោះបីជា តាភឹម ក៏ត្រូវតស៊ូដែរ។ គាត់ធ្លាប់និយាយថា យើងនឹងមានការបង្ហូរឈាមបន្ថែមទៀត ប៉ុន្តែមិនមានឱកាសនឹងធ្វើបែបនោះទេ។ ឱកាសដែលយើងតស៊ូនោះ គឺកើតមានឡើងនៅពេលដែលយើងឃើញមានការកែប្រែមួយចំនួន ហើយអ៊ីចឹងហើយ យើងបានធ្វើរដ្ឋប្រហារជាដំបូងដើម្បី (ចំណុចត្រង់នេះមិនច្បាស់ទេ ជាភាសាខ្មែរ)។ នៅពេលដែលគេធ្វើបែបនេះ យើងបានចាប់យក

ឱកាស ដើម្បីងើបឡើងតស៊ូ ដោយហេតុថា តាភឹម មានជំងឺ ហើយគេបញ្ជូនគាត់ទៅប្រទេសចិនដើម្បីព្យាបាល។” នៅខាងក្រោមនេះបន្តិច “មុនពេលរដ្ឋប្រហារ ខ្ញុំនៅជាមួយគាត់។ នៅពេលដែលគាត់ចេញបញ្ជាឲ្យច្បាំង ប៉ុល ពត ខ្ញុំនៅជាមួយគាត់ ហ្នឹងជាការច្បាស់ណាស់។” សូមចប់សេចក្ដីដកស្រង់។

លោកសាក្សី នេះជាសម្ដីរបស់លោក ហេង សំរិន គឺថាគាត់និយាយអំពីការតស៊ូសម្ងាត់នៅក្នុង ១៩៧៦ និង១៩៧៧។ តើលោកធ្លាប់ឮអំពីការតស៊ូសម្ងាត់នៅក្នុងភូមិភាគបូព៌ាដែរឬទេ ដែលដឹកនាំដោយ សោ ភឹម ហើយលោក ហេង សំរិន ហើយនិងអ្នកផ្សេងទៀតនោះ?

[០៩:៣៨:២៨]

**ឆ៖** បាទ អរគុណ។ ខ្ញុំមិនធ្លាប់ឮទេ។

**ស៖** តើលោកធ្លាប់ឮពីកងកម្លាំងលោក ហេង សំរិន ដែលថាវាយប្រហារប្រឆាំងនឹងកងកម្លាំងមកពីមជ្ឈិមជាច្រើនលើកដែរឬទេ<>?

**ឆ៖** ពេលណា?

**ស៖** បាទ បន្ទាប់ពីថ្ងៃទី២៥ ឧសភា ឆ្នាំ១៩៧៨ តើមានការប៉ះទង្គិចរវាងកងកម្លាំងលោក ហេង សំរិន ហើយនិងកងកម្លាំងយោធាមកពីមជ្ឈិម គឺការប៉ះទង្គិចគ្នានៅភូមិភាគបូព៌ា?

**ឆ៖** អរគុណ។ ក្រោយថ្ងៃ២៥ ខែ៥ ឆ្នាំ១៩៧៨ មិនមែនតែកងកម្លាំងលោក ហេង សំរិន ទេ។ និយាយរួមកម្លាំងទាំងអស់សុទ្ធតែរត់គេច ហើយនិងតស៊ូប្រឆាំងនឹងកម្លាំងមជ្ឈិមដែលតាមចាប់សម្លាប់អ្នកបូព៌ា។ អរគុណ។

**ស៖** តើលោកដឹងទេ ថាមានការប៉ះទង្គិចខាងយោធាចំនួនប៉ុន្មានក្រោយពីថ្ងៃទី២៥ ឧសភា ១៩៧៨មក <មុនពេលកងទ័ពវៀតណាមចូលមកដល់>? តើកងកម្លាំងរបស់លោក ហេង សំរិន ហ្នឹងវាយប្រយុទ្ធជាមួយកងកម្លាំងរបស់មជ្ឈិមហ្នឹងប៉ុន្មានដងដែរ តាមដែលលោកដឹង ឬក៏ចាំ?

**ឆ៖** ខ្ញុំមិនចាំប៉ុន្មានដងទេ ប៉ុន្តែកន្លែងនីមួយៗឲ្យតែពួកកងទ័ពរបស់មជ្ឈិមចូលទៅរកចាប់ ទៅដេញគេ ទៅចូលកន្លែងគេ កន្លែងអ្នកនៅបូព៌ាហ្នឹង ឲ្យតែមានអាវុធសុទ្ធតែតតាំង ឬនឹងរត់គេៀសខ្លួនចេញពីកន្លែងរបស់ខ្លួន។ ដូច្នេះក្រោយថ្ងៃ២៥ គឺយ៉ាងដូច្នេះឯង ២៥ ខែ៥ ឆ្នាំ១៩៧៨ គឺអ្នកបូព៌ាទាំងអស់ត្រូវតែរត់គេចខ្លួន អរគុណ។

[០៩:៤១:៣០]

**ស៖** ប៉ុន្តែខ្ញុំចង់សួរថាតើកងទ័ពដែលដឹកនាំដោយលោក ហេង សំរិន វាយប្រហារប្រឆាំងមក

វិញទេ ក្រោយពីថ្ងៃទី២៥ ឧសភា ១៩៧៨ នោះ?

**ឆ៖** មានការវាយប្រឆាំងវិញ ជាទូទៅលក្ខណៈដោយឡែកៗពីគ្នាតាមកន្លែងរៀងៗខ្លួន បាទ។

**ស៖** តើលោកដឹងកងកម្លាំងរបស់លោក ហេង សំរិន នៅពេលណាមួយ គឺមានកងកម្លាំងរបស់វៀតណាមចូលមកជួយ ដើម្បីធ្វើការវាយប្រហារដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ពេលវេលា តែដឹងថានៅក្នុងចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩។ អរគុណ។

**ស៖** ខ្ញុំត្រឡប់មកខែឧសភា ឆ្នាំ១៩៧៨។ ពីម្សិលមិញលោកនិយាយផងដែរពីរឿងនេះ ប៉ុន្តែខ្ញុំយោងទៅរកអ្វីដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតក្នុងឯកសារ E3/5531 សំណួរនិងចម្លើយ៦២។ ខ្ញុំនឹងអានជូនលោកស្ដាប់៖ "នៅពេលល្ងាច ខ្ញុំបានទទួលសំបុត្រមួយពី សោ ភឹម ហើយគឺជាអ្នកបើកបររបស់គាត់ ជាអ្នកយកមកឱ្យខ្ញុំ ឈ្មោះ សំ។ សំបុត្រនោះនិយាយ និងគេជូនទៅលោក ស ហើយនិងសមមិត្តស, សមមិត្តសឿន។ សុំឱ្យរៀបទ័ពឱ្យបានជាស្រេច ដើម្បីវាយប្រហារ ដើម្បីការពារកងកម្លាំងយើងកុំឱ្យគេចាប់ខ្លួន។ ផ្អែកតាមការប៉ាន់ប្រមាណរបស់យើង នឹងមានរដ្ឋប្រហារយោធាដឹកនាំដោយ សុន សេន ដើម្បីផ្ដួលលេខា និងអនុលេខបក្ស។" ចប់សេចក្ដីដកស្រង់។ លោកសាក្សី លោកនិយាយពីសំបុត្រមកពី សោ ភឹម និយាយពីរឿងថា សោ ភឹម គិតថា សុន សេន បានរៀបចំធ្វើរដ្ឋប្រហារប្រឆាំងនឹង ប៉ុល ពត, នួន ជា។ តើលោកធ្លាប់ឮពីមូលហេតុអ្វីមួយទេ ដែល <សោ ភឹម គិត>ថា សុន សេន ជាអ្នករៀបចំធ្វើរដ្ឋប្រហារដើម្បីផ្ដួល ប៉ុល ពត និង នួន ជា នោះ?

[០៩:៤៤:៣៩]

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ពីព្រោះថាសំណួរនេះសុំឱ្យសាក្សីឆ្លើយស្មានក្នុងនាមគាត់ជា សោ ភឹម ហើយ។ អ៊ីចឹងសុំឱ្យមេធាវីការពារក្ដីរៀបសំណួរផ្សេង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងសម្រួលសំណួរឡើងវិញ មិនបញ្ហាទេ។

**ស៖** លោកសាក្សី តើលោកបានឮពី សោ ភឹម ឬក៏ឮពីឪពុករបស់លោក ឬក៏ឮពីអ្នកណាម្នាក់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មូលហេតុអ្វីដែល សោ ភឹម គិតថា សុន សេន រៀបចំធ្វើរដ្ឋប្រហារប្រឆាំង ប៉ុល ពត និង នួន ជា?

**លោក មាស សឿន៖**

**ឆ៖** បាទ ព្រោះនៅក្នុងភូមិភាគបូព៌ាទាំងមូល ត្រូវកម្លាំងទ័ពមជ្ឈិមបោសសម្អាតទាំងអស់ចាប់ពីព្រឹកថ្ងៃទី២៥ ខែ៥ទៅ គ្រប់ផ្លូវ គ្រប់អីទាំងអស់ អ្នកធ្វើដំណើរតាមផ្លូវ ត្រូវបានកងទ័ពមជ្ឈិមចាប់យកទៅឃុំខ្លួននៅក្នុងព្រះវិហារវត្ត វិហារទន្ទឹម ទីក្រុងស្វាយបច្ចុប្បន្ននេះ។ បាទ អរគុណ។

**ស៖** បាទ ខ្ញុំយល់។ ប្រហែលជាលោកដឹងពីមូលហេតុអីដែលថា សោ ភឹម គិតថា សុន សេន គឺជាអ្នកប្រឆាំង ប៉ុល ពត និង នួន ជា នោះ?

[០៩:៤៦:៣៣]

**ឆ៖** អរគុណ។ ខ្ញុំមិនដឹងទេ។

**ស៖** ខ្ញុំនឹងអាចអានភស្តុតាងផ្សេងទៀត អាចនឹងរំឭកការចងចាំ ឬក៏ធ្វើឲ្យលោកនឹកឃើញពីរឿងហេតុមួយចំនួន។ នេះគឺជា<>សក្ខីកម្មរបស់លោក ហេង សំរិន E3/1568 ខ្មែរ 00713980, អង់គ្លេស 00651899, បារាំង 00743378។ នេះជាអ្វីដែលលោក ហេង សំរិន បាននិយាយ ឆ្លើយទៅលោក ប៊ែន ឃៀរនិន សូមដកស្រង់៖ "មានពួកយើងមួយចំនួនតូចនៅក្នុងកិច្ចប្រជុំ <មិនមែនគ្រប់ស្រុកទាំងអស់បានចូលរួមទេ គឺមានតែស្រុកមួយចំនួនតែប៉ុណ្ណោះ។> គឺនៅក្នុងកិច្ចប្រជុំនោះ គឺប្រហែលជាប្រើពេល២ម៉ោង។ យើងបានពិភាក្សាពីស្ថានភាពទូទៅ ពីហេតុការណ៍ទូទៅ។ ជាទូទៅ តាភឹម គឺ<>នៅ<>មាន<ការស្ទាក់ស្ទើរ>នៅឡើយនៅពេលនោះ ហើយគាត់មិនជឿខ្ញុំទេ។ បើគាត់ជឿខ្ញុំនៅពេលនោះ គាត់អាចនឹងនៅរស់បាន ពីព្រោះគាត់ជឿជាក់ទៅលើ ប៉ុល ពត។ គាត់និយាយថា រដ្ឋប្រហារគឺជារដ្ឋប្រហាររបស់ សុន សេន។ គឺសុន សេន ធ្វើរដ្ឋប្រហារដើម្បីផ្តួល ប៉ុល ពត ប៉ុន្តែខ្ញុំនិយាយថា មិនមែនសុន សេន ទេ គឺនយោបាយរបស់ ប៉ុល ពត ទេ។ គឺច្បាស់ណាស់ ប៉ុល ពត មាននយោបាយសម្រិតសម្រាំងគឺភ្នាក់ងារនៅក្នុងជួរបក្ស។ យើងបានអានឯកសារនិយាយអំពីភ្នាក់ងារនៅក្នុងជួរ។ អ៊ីចឹងយើងឃើញច្បាស់ណាស់។ <ពួកគេបានធ្វើបែបនេះនៅគ្រប់>ភូមិភាគទាំងអស់<រួចទៅហើយ លើកលែងតែនៅ>ភូមិភាគបូព៌ា<ទេ>។ <វាជាភូមិភាគចុងក្រោយ។ នៅពេលនោះ សកម្មភាពចុងក្រោយរបស់> ប៉ុល ពត គឺនឹងប្រើជាយន្តការក្នុងរូបភាពជារដ្ឋប្រហារ។ ខ្ញុំបានប្រាប់ <ភឹម> ពីរឿងនេះ ប៉ុន្តែគាត់មិនជឿខ្ញុំទេ។ គាត់និយាយថា គាត់នៅមានសង្ឃឹមលើបងលេខ១។ នៅពេលដែលយើងវាយប្រយុទ្ធយ៉ាងខ្លាំងប្រឆាំង ប៉ុល ពត នៅពេលនោះ លោក សោ ភឹម បានសុំឲ្យខ្ញុំផ្អាកការប្រឆាំងនៅពេលនោះ។" សូម

ចប់សេចក្ដីដកស្រង់។ តើនេះជាអ្វីដែលធ្វើឲ្យលោកនឹកឃើញពីរឿងហេតុនៅពេលនោះទេ លោកសាក្សី?

[០៩:៤៩:៣៩]

**ឆ៖** ខ្ញុំដឹងថាព្រឹត្តិការណ៍ក្រោយថ្ងៃ២៥ ខែ៥ ឆ្នាំ១៩៧៨ ខ្ញុំមិនដែលជួបមុខ សោ ភឹម ទេក្រៅតែពីលិខិត ហើយនិងការណែនាំឲ្យខ្ញុំប្រយុទ្ធ។ បន្ទាប់មកទៀត លោកប្រធានខ្ញុំឈ្មោះ ស បានណែនាំឲ្យខ្ញុំផ្អាកប្រយុទ្ធ តែមិនឲ្យប្រគល់ខ្លួន ឬប្រគល់អាវុធឲ្យពួកមជ្ឈិមទេ ត្រូវរក្សាកម្លាំងទុកសិន ព្រោះរង់ចាំ សោ ភឹម ទៅភ្នំពេញដើម្បីដោះស្រាយ។ អរគុណ។

**ស៖** តើលោកធ្លាប់ឮពីផែនការដែលរៀបចំឡើងដោយលោក ហេង សំរិន ដើម្បីនាំយក សោ ភឹម ទៅខាងកើត ទៅភូមិភាគបូព៌ាហ្នឹងដើម្បីយកគាត់ទៅវៀតណាម លោកធ្លាប់ឮទេ ផែនការនេះ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ។ អរគុណ។

**ស៖** នៅក្នុង ERN ដដែលលោកប្រធាន គាត់និយាយថា៖ "តាម ហេង សំរិន ផែនការគឺយកតាភឹម ទៅភូមិភាគខាងកើតដើម្បីយកគាត់ចេញទៅប្រទេសវៀតណាម។" ចប់សេចក្ដីដកស្រង់។ លោកសាក្សីទំនងជាលោកមិនដឹងអ្វីច្រើនទេ ខ្ញុំបញ្ចប់ដោយសួរលោកនូវសំណួរតូចៗមួយចំនួន។ នៅក្នុងចម្លើយរបស់លោកទៅសំណួរទី៣៨ នៅក្នុងបទសម្ភាសន៍របស់លោកទៅសហចៅក្រមស៊ើបអង្កេតហ្នឹង គឺថាវៀតណាមវាយប្រហារ<ជាលើកដំបូង>នៅឆ្នាំ១៩៧៧ ដែល<លោក>ហៅថា <ការវាយប្រហារលើកដំបូងរបស់>យួន<>នៅក្នុងឆ្នាំ១៩៧៧។ តើលោកចាំបានអ្វីខ្លះពីសម្ដីរបស់លោកកាលនិយាយពេលនោះ?

**ឆ៖** បាទ ខ្ញុំចាំ។ ឆ្នាំ១៩៧២ ក្នុងចុងឆ្នាំ កងទ័ពវៀតណាមបានវាយចូលដល់ភូមិដំណាក់ចារ ឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ជិតដល់ផ្សារស្នួងនៅប្រហែលជា១០គីឡូទៀតដល់ផ្សារស្នួងបច្ចុប្បន្ន។ អរគុណ។

[០៩:៥២:៣៥]

**ស៖** ខ្ញុំឮនៅក្នុងថា ១៩៧២ ប៉ុន្តែលោកសាក្សីថា១៩៧៧ទេ អ៊ីចឹងឬក៏ការបកប្រែហ្នឹងល្អៀង?

**ឆ៖** បាទ ៧៧ ប្រហែលជាច្រឡំ។ ចិតសិបប្រាំពីរ គឺចិតសិបប្រាំពិលនេះឯង។ អរគុណ។

**ស៖** ដើម្បីឲ្យប្រាកដគឺ ខ្ញុំអានសំណួរចម្លើយ៣៨ គឺថា "មន្ទីរសន្តិសុខគឺស្ថិតនៅក្នុង<ភូមិខ្នុរ> ចាស់នៅស្រុកដំបែ បន្ទាប់ពីការវាយប្រហាររបស់យួននៅក្នុងឆ្នាំ១៩៧៧ មន្ទីរសន្តិសុខត្រូវបានប្ដូរទៅកន្លែងមួយនៅចន្លោះស្រុកពញាក្រែក និងស្រុកត្បូងឃ្មុំនៅខាងកើតផ្លូវទៅឆ្លូង នៅ<ភូមិ>ត្រពាំង

<សង្កែ>”។ តើហេតុការណ៍នេះលោកនិយាយអំពីឆ្នាំ១៩៧៧?

**ឆ៖** បាទ ៧៧ ដែលក្រោយពីវៀតណាមវ៉ៃចូលដល់ ជិតដល់ស្រុកត្បូងឃ្មុំហើយ ក្រោយមកដកថយទៅវិញ។ អរគុណ។

**ស៖** តើលោកនៅចាំដែរឬទេ នៅក្នុងឆ្នាំ១៩៧៧ដែលវៀតណាមវាយប្រហារមកកម្ពុជានោះ នៅខែណា ឬក៏ថ្ងៃណា លោកចាំទេ?

**ឆ៖** ខ្ញុំចាំថារដូវប្រាំងមានស្រូវទុំ តែមិនប្រាកដខែទេ។ អរគុណ។

**ស៖** តើលោកនៅចាំអ្វីជាលម្អិតទេ ការវាយប្រហារលើកដំបូងរបស់វៀតណាមនៅក្នុងឆ្នាំ ១៩៧៧? តើមាន<មនុស្ស>របួស ឬក៏ស្លាប់<ច្រើនទេ? តើមានអ្វីកើតឡើងនៅសមរភូមិ>? តើលោកអាចជម្រាបតុលាការបន្តិចបានទេ?

[០៩:៥៥:00]

**ឆ៖** អរគុណ។ ខ្ញុំមិនប្រាកដថាខូចខាតអី ស្លាប់ ឬ របួសយ៉ាងណានោះទេ។ បាទ អរគុណ។

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ គឺនិយាយអំពី សោ ភឹម គឺបញ្ហាទាក់ទងពីគ្រួសាររបស់ សោ ភឹម។ តើលោកដឹងទេលោកសាក្សី តើ សោ ភឹម គាត់មានកូនស្រីដែរទេ ដែលរៀបការជាមួយកូនប្រុសរបស់<ប្រធាន>ភូមិភាគពាយ័ព្យ ឈ្មោះ តាជាល? គឺជា អាចជាកូនរបស់លោក រស់ ញឹម ដែលរៀបការមួយកូនស្រី សោ ភឹម។ តើលោកដឹងអំពីរឿងនេះទេ?

**ឆ៖** បាទ គ្រាន់តែដឹងថា សោ ភឹម ជាដន្លងជាមួយនឹង រស់ ញឹម។ តែមិនដឹងថាកូនប្រុស រស់ ញឹម អ្នកណានោះទេ។ អរគុណ។

**ស៖** ម្សិលមិញ<>សហព្រះរាជអាជ្ញាបានបង្ហាញឯកសារ ដែលមានហត្ថលេខា សោ ភឹម ហើយឯកសារនេះគេមានថា ទៅជួបជាមួយ រស់ ញឹម។ ថាតើលោកដឹងថា លោក សោ ភឹម ធ្វើដំណើរជាញឹកញាប់ទៅភូមិភាគពាយ័ព្យ ដើម្បីទៅជួប រស់ ញឹម ដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំមិនបានដឹងទេ។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុងក្រោយអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក

ខៀវ សំផន ដើម្បីសួរសំណួរដេញដោលចំពោះសាក្សី។

[០៩:៥៧:២០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ គង់ សំអុន ជាមេធាវីជាតិការពារលោក ខៀវ សំផន។ ហើយតទៅនេះ ខ្ញុំមានសំណួរសូមឲ្យលោកជួយបញ្ជាក់ខ្លីទេ។ កាលពីម្សិលមិញ នៅម៉ោងប្រហែលជាម៉ោង០៤:៣៩នាទី ហើយនិងនៅម៉ោង១៥:៣០ លោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា និងលោកមេធាវី កូប៉េ ទាក់ទងទៅនឹងការជួបឪពុករបស់លោក គឺមានពីរដង។ គឺមានម្ដងនោះ គឺជួបនៅឈើកាច់ ហើយនិងម្ដងទៀតជួបនៅអ្នកលឿង។ ហើយលោកបានបញ្ជាក់ផងដែរថា លោកមិនសូវជាបានជួបឪពុករបស់លោកទេ ហើយទោះបីជាក្នុងលក្ខណៈគ្រួសារក៏ដោយ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា តើព្រឹត្តិការណ៍ទាំងពីរនេះដែលលោកបានជួបនេះ ជាព្រឹត្តិការណ៍ពីរដោយឡែកពីគ្នា ឬក៏ជាព្រឹត្តិការណ៍តែមួយទេ។ លោកអាចបញ្ជាក់បានទេ?

**លោក មាស សឿន៖**

**ឆ៖** អរគុណ។ ព្រឹត្តិការណ៍ខុសគ្នា ពីរដង។ អរគុណ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល គឺចាប់ពីឆ្នាំ១៩៧៥ រហូតដល់ដើមឆ្នាំ៧៩ហ្នឹង តើលោកជួបឪពុករបស់លោកបានប៉ុន្មានដង លោកអាចបញ្ជាក់បានទេ?

**ឆ៖** អរគុណ។ ខ្ញុំមិនចាំទេ។

[០៩:៥៩:១៩]

**ស៖** បាទ សូមអរគុណ។ នៅដំណាក់កាលដំបូង នៅពេលដែលទទួលបានជ័យជម្នះ១៧ មេសា ១៩៧៥ ហើយលោកបានទៅធ្វើការនៅរោងជាងក្រឡឹង ហើយនៅពេលនោះដែរ នៅក្នុងឆ្នាំដដែលនោះ លោកត្រូវបានបញ្ជូនមករៀននៅសាលាបច្ចេកទេសឫស្សីកែវ តាមសក្ខីកម្មរបស់លោក។ ក្នុងអំឡុងពេលហ្នឹង លោកដែលបានជួបឪពុករបស់លោកផ្ទាល់ទេ នៅពេលដែលលោកមករៀននៅឫស្សីកែវ?

**ឆ៖** អរគុណ។ ខ្ញុំមិនដែលជួបទេ ក្នុងរយៈកាលដែលខ្ញុំមករៀននៅឫស្សីកែវនេះ។ អរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** បាទ សូមអរគុណ។ នៅពេលដែលលោកត្រឡប់ទៅភូមិភាគបូព៌ាវិញ ហើយលោកទៅធ្វើការនៅរោងជាងក្រឡឹង ក្នុងការងាររបស់លោកនុ៎ង លោកបានជួបញឹកញាប់ប៉ុនណាដែរ ក្នុងឆ្នាំដំបូង ហើយនិងឆ្នាំបន្តបន្ទាប់ទៀត លោកអាចបញ្ជាក់បានទេ?

**ឆៈ** គ្មានសូវបានជួបទេ ជាមួយឪពុករបស់ខ្ញុំ ព្រោះជាការងាររៀងខ្លួន។ អរគុណ។

**សៈ** បាទ សូមអរគុណ។ ក្រៅពីព្រឹត្តិការណ៍ពីរដែលលោកបានជួបឪពុករបស់លោកនៅអ្នកលឿង និងនៅឈើកាច់ហ្នឹង លោកចាំបានព្រឹត្តិការណ៍ណាមួយផ្សេងទៀត ឬក៏ច្រើនដែលលោកបានជួបឪពុករបស់លោកដែរទេ?

**ឆៈ** បាទ អរគុណ។ ខ្ញុំមិនច្បាស់ទេ។ សូមអរគុណបាទ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលលោកថា បានជួបឪពុករបស់លោកនៅឈើកាច់២ខែក្រោយថ្ងៃ២៥ ឧសភា ឆ្នាំ១៩៧៨ លោកអាចបញ្ជាក់ពីកាលបរិច្ឆេទជាក់លាក់បានទេនៅពេលហ្នឹង?

[១០:០២:១២]

**ឆៈ** បាទ ខ្ញុំមិនអាចបញ្ជាក់ជាក់លាក់បានទេ ព្រោះក្នុងចម្លើយរបស់ខ្ញុំ ក៏ប្រហាក់ប្រហែលដែរ តែខ្ញុំគ្រាន់តែចាំថា ក្រោយព្រឹត្តិការណ៍ថ្ងៃ២៥ ខែ៥ ឆ្នាំ១៩៧៨ គ្រាន់តែចាំប៉ុណ្ណឹង។ អរគុណ។

**សៈ** បាទសូមអរគុណ។ ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់លោកលេខ E3/5531 ត្រង់សំណួរចម្លើយលេខ៤៣ ជាភាសាខ្មែរ ហើយជាភាសាអង់គ្លេស ឬបារាំងប្រហែលនៅ៤២ ពីព្រោះភាសាខ្មែរវាលោតមួយលេខ។ លោកបានបញ្ជាក់អំពីការស្នើសុំទៅ សោ ភឹម ឲ្យមានការដោះលែងមនុស្សប្រហែល៤០នាក់ដែលលោកបានឆ្លើយថា មេរបស់លោកមិនហ៊ានទៅជួបទេ ហើយមានការភ័យខ្លាច ហើយក៏ផ្តល់ភារៈនេះឲ្យលោកដើម្បីទៅជួបផ្ទាល់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកនៅគាំទ្រនូវសក្ខីកម្មរបស់លោក ដែលបញ្ជាក់ថា ខ្ញុំសូមដកស្រង់ សូមអានជូន ត្រង់ចម្លើយលេខ៤៣៖ "ពេលនោះខ្ញុំចាំបានថា ខ្ញុំក៏បានប្រតិកម្មតបវិញ ដោយសួរគាត់ថា គំនិតរបស់បង (គឺឈ្មោះ ស) យល់យ៉ាងម៉េច? ឈ្មោះ ស បានឆ្លើយថា ខ្ញុំមិនជឿថា ពួកនេះក្បត់ទេ ព្រោះពួកនេះមិនដែលចាត់តាំងឲ្យទៅធ្វើការនៅព្រំដែនយួនទេ។ បន្ទាប់មកយើងបានពិភាក្សាគ្នា កោះប្រជុំប្រធានអង្គភាពក្រោមឱវាទ ដោយធ្វើកំណត់ហេតុពីគ្រប់អង្គភាព។ បន្ទាប់ពីមានការប្រជុំរួចមក យើងបានសម្រេចថាយើងធ្វើលិខិតធានានិងបញ្ជាក់ថា អ្នកទាំងអស់នោះមិនក្បត់ទេ។ សូមឲ្យ សោ ភឹម រក្សាទុកអ្នកទាំងនោះ នៅក្នុងអង្គភាពដើម។"

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកចាំសក្ខីកម្មនេះ ដែលលោកបានផ្តល់ជាមួយនឹងចៅក្រមស៊ើបអង្កេតទេ?

[១០:០៥:៤១]

**ឆ៖** បាទ ខ្ញុំចាំ។ អរគុណ។

**ស៖** តើលោកដឹងពីមូលហេតុដែលនាំឲ្យមានការចាប់ខ្លួនអ្នកទាំងនោះដែរនៅពេលនោះ?

**ឆ៖** អរគុណ។ ខ្ញុំមិនដឹងពីមូលហេតុនោះទេ។ អរគុណ។

**ស៖** បាទ សូមអរគុណ។ លោកដឹងថា អ្នកណាអ្នកធ្វើសេចក្តីសម្រេចក្នុងការចាប់អ្នកទាំងអស់នោះដែរទេ នៅពេលហ្នឹង?

**ឆ៖** ខ្ញុំមិនធ្លាប់ឃើញសេចក្តីសម្រេចចាប់ខ្លួននោះទេ តែលោកប្រធានអង្គភាពខ្ញុំឈ្មោះ ស គាត់បានប្រាប់ខ្ញុំថា ឈ្មោះ យិន សុភី ជាអ្នកមកប្រាប់គាត់ ថាត្រូវឲ្យអង្គភាពយើងនេះចូលរួមសហការឲ្យកម្លាំងរបស់សន្តិសុខ យិន សុភី មកចាប់អ្នកទាំងអស់នោះ។ អរគុណ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការសម្រេចមិនឲ្យចាប់ ដែលនៅពេលក្រោយពេលដែលលោកទៅជួប សោ ភឹម តើលោកបានឃើញ ឬក៏ដឹងថាលោក សោ ភឹម គាត់សម្រេចដោយខ្លួនឯងថាមិនឲ្យចាប់ ឬក៏មានទំនាក់ទំនងណាមួយដែលលោក សោ ភឹម ទាក់ទងទៅថ្នាក់លើណាទៀតដើម្បីស្នើសុំថាមិនឲ្យចាប់ដែរទេ?

**ឆ៖** អរគុណ។ ត្រង់គាត់ទៅទាក់ទងនៅថ្នាក់ណា ខ្ញុំមិនដឹងទេ ព្រោះខ្ញុំបាទបានជួបតែ សោ ភឹម តែប៉ុណ្ណោះ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីការធ្វើសេចក្តីសម្រេចរបស់គាត់បានទេ តើគាត់សម្រេចភ្លាមៗ ឬមួយក៏មានទុករយៈពេលណាមួយដើម្បីគាត់ពិចារណាមុនពេលធ្វើការសម្រេច?

[១០:០៨:២៥]

**ឆ៖** អរគុណ។ ខ្ញុំគ្រាន់តែចាំបានថា ក្រោយពីខ្ញុំរាយការណ៍ចប់សព្វគ្រប់ លោក សោ ភឹម បានសួរខ្ញុំថា ការសុំលើកលែងនិងធានាអ្នកទាំងអស់នេះ ជាគំនិតរបស់អ្នកណា? ខ្ញុំបានជម្រាបគាត់ថា ជាគំនិតរបស់គណៈកម្មាធិការសាខាបក្សអង្គភាពរោងក្រឡឹងទាំងមូលដែលបានប្រជុំ និងចុះហត្ថលេខារួមគ្នា។ អរគុណ។

**ស៖** បាទ សូមអរគុណ។ ហើយក្រោយមកគាត់សម្រេចយ៉ាងដូចម្តេច? លោកអាចបញ្ជាក់ពីសម្តីរបស់គាត់បានទេ?

**ឆ៖** គាត់បានប្រាប់ខ្ញុំថា គាត់ជាអ្នកគ្រប់គ្រងបណ្តាសមមិត្តទាំងអស់នោះដោយប្រយោល។ គាត់ក្តាប់តែប្រវត្តិរូបនិងរបាយការណ៍តែប៉ុណ្ណោះ។ បើបណ្តាសមមិត្តជាអ្នកគ្រប់គ្រងផ្ទាល់ដល់អ្នកទាំងជាង៤០នាក់នោះ ខ្ញុំឯកភាពតាមសំណូមពររបស់បណ្តាសមមិត្តនៅអង្គភាពនោះ។ អរគុណ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរមួយទៀត ទាក់ទងទៅនឹងជនជាតិចាមដែលលោកបានបញ្ជាក់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/5531 ត្រង់សំណួរចម្លើយលេខ៥០។ បាទ ដោយសារវាលោតលេខ អ៊ីចឹងជាភាសាខ្មែរមកលេខ៥១ ហើយជាភាសាបរទេសអង់គ្លេស និងបារាំងនៅលេខ៥០ដដែល។ លោកបានបញ្ជាក់ថា លោកឮតៗគ្នាថា ជនជាតិចាមនៅកោះផល មានការបះបោរ។ តើលោកនៅចាំសក្ខីកម្មនេះទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំចាំ។

[១០:១២:៣១]

**ស៖** លោកបានបញ្ជាក់រួចហើយ ថាលោកមិនបានឃើញការបះបោរនោះដោយផ្ទាល់ទេ តែលោកបានឃើញការជម្លៀសជនជាតិចាមទៅនៅស្រុកដំបែ។ ខ្ញុំចង់សួរលោកបន្ថែមថា តើការជម្លៀសជនជាតិចាមនៅពេលនោះ គឺមានតែចាម ឬក៏មានជនជាតិខ្មែរ ឬក៏ជនជាតិដទៃផងដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ អរគុណ។ ជាទូទៅនៅក្នុងតំបន់ភូមិភាគបូព៌ាទាំងមូល មានការជម្លៀសទាំងអស់តាំងពីឆ្នាំ១៩៧៥ ក្រោយ ១៧ មេសា ១៩៧៥ផងមានជម្លៀសវិលទៅវិលមក ទាំងអស់គ្មានអ្នកណាបាននៅផ្ទះ និងស្រុកកំណើតរបស់ខ្លួនទេ ប៉ុន្តែជនជាតិចាម ក៏បានឃើញទៅដល់ តាមព្រៃនៅខាងស្រុកដំបែឯណោះ។ អរគុណ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងចម្លើយលេខ៥១ នៅក្នុងសក្ខីកម្មរបស់លោកនេះផងដែរ លោកបានប្រើពាក្យថា "មានការបោសសម្អាតជនជាតិចាម"។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ពីខ្លឹមសារនៃការដែលលោកនិយាយថា "បោសសម្អាតជនជាតិចាម" នេះលោកសំដៅលើន័យបែបម្តេច លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ "បោសសម្អាត" នេះចង់និយាយលើន័យថា អ្នកនៅកោះផលទាំងអស់នេះ ក្រោយពីមានព្រឹត្តិការណ៍នេះ គ្មានបងប្អូនចាមណានៅកោះផលទៀតទេ គឺជាកោះទទេ ជម្លៀសចេញអស់ហើយអ្នកស្រុក បងប្អូនចាមនៅទីនោះ។ អរគុណ។

[១០:១៥:០០]

**ស៖** បាទ សូមអរគុណ។ ជាចុងក្រោយ ខ្ញុំចង់បញ្ជាក់លោកទៅលើតួនាទីរបស់លោក ខ្ញុំឃើញលោកមានប្រើប្រាស់ពាក្យពីរខុសគ្នា។ ទី១ គឺការងាររបស់លោកជាអនុប្រធានសិប្បកម្មរោងជាងក្រឡឹង និងមួយទៀត ឃើញប្រើពាក្យអនុប្រធានរោងចក្រៗក្រឡឹង។ តើលោកអាចបញ្ជាក់បានទេថាមួយណាដែលជាតួនាទីរបស់លោកពិតប្រាកដនៅពេលដែលក្រោយ ក្រោយពេលដែលលោករៀនចប់ពីសាលាបច្ចេកទេសឫស្សីកែវទៅ? ជារោងចក្រ ឬក៏ជារោងជាង លោកអាចបញ្ជាក់បានទេ?

**ឆ៖** អរគុណ។ ខាងរោងក្រឡឹងនេះ បើនិយាយឲ្យច្បាស់ទៅ គឺរបស់ភូមិភាគបូព៌ា មានតែរោងចក្រក្រឡឹងរបស់ខ្ញុំនេះហើយ ឬក៏រោងជាងក្រឡឹងនេះហើយ គឺរោងជាងនិងរោងចក្រក្រឡឹងនេះតែមួយនេះទេ។ ខ្ញុំធ្វើការតែមួយកន្លែងនេះទេ។ អរគុណ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំយល់ពីបញ្ហានេះ តែលោកអាចបញ្ជាក់បានទេថា នៅពេលនោះគេប្រើថាជារោងចក្រក្រឡឹង ឬក៏រោងជាងក្រឡឹង។ លោកអាចបញ្ជាក់ឲ្យច្បាស់ចំណុចនេះបានទេ?

**ឆ៖** អរគុណ។ គេប្រើពាក្យ កាលនុំងភាគច្រើនគេប្រើពាក្យថា “ឧស្សាហកម្មក្រឡឹងរបស់ភូមិភាគបូព៌ា”។ អរគុណ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ អរគុណលោកសាក្សី។

[១០:១៧:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោកសាក្សី។ បាទ អង្គជំនុំជម្រះអរគុណលោក មាស សឿន សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនាពេលនេះដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខសេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរចំពោះលោកស្រី សុក សុជាតា ជាមេធាវីប្រឹក្សាសាក្សី ហើយលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នក

ជំនាញជូនលោក មាស សឿន វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏ដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយសវនាការនៅថ្ងៃនេះដល់ពេលត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី២៦ ខែកក្កដា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃអង្គារ ទី២៦ កក្កដា ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-1005 ពាក់ព័ន្ធនឹងបរិបទអង្គហេតុចោទប្រកាន់ការបោសសម្អាតផ្ទៃក្នុង សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ជម្រាបជូនសាធារណជនជ្រាបផងដែរថា រយៈពេលបីសប្ដាហ៍ពីថ្ងៃទី០៤ ដល់ទី២២ ដើមខែកក្កដា ឆ្នាំ២០១៦ អង្គជំនុំជម្រះមិនធ្វើសវនាការទេ ដោយជារយៈពេលវិស្សមកាលតុលាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោកខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃអង្គារ ទី២៦ ខែកក្កដា ឆ្នាំ២០១៦ ដោយបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១០:១៨ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*